# ៣. ការកសាងសមត្ថភាព និង ការអភិវឌ្ឍស្ថាប័ន

## ៣.១. សកម្មភាពកសាងសមត្ថភាពសំខាន់ៗ

ក្រសួងអប់រំ យុវជន និងកីឡា បានចាត់វិធានការអនុវត្តតាមអនុសាសន៍មួយចំនួនដែលបានលើកឡើងនាពេលពិនិត្យឡើងវិញឆ្នាំ ២០០៣ រួមមាន :

- អនុវត្តគោលវិធីទូលំទូលាយនិងមានលក្ខណៈសម្របសម្រួល ដល់ផែនការសកម្មភាពសម្រាប់ការកសាងសមត្ថភាពនិងការអនុវត្តកម្មវិធី តាមរយៈក្រុមសម្របសម្រួលការកសាងសមត្ថភាពនៅអគ្គនាយកដ្ឋានអប់រំ និង អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ដែលការងារនេះបានដំណើរការជាប្រចាំនិងទទួលបានលទ្ធផលល្អ ។
- ក្រសួងបានបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីអប់រំនិងបទប្បញ្ញត្តិនានា ហើយកំពុងសុំការអនុម័តជាបន្តបន្ទាប់ពីដើមឆ្នាំ២០០៥មក ព្រមទាំងរំពឹងថាច្បាប់ស្តីពីអប់រំនឹងបានដាក់ជូនរដ្ឋសភាអនុម័តនៅពេលខាងមុខ ។
- បានធ្វើការពង្រីកកម្មវិធីបំប៉នបុគ្គលិករដ្ឋបាលថ្នាក់កណ្តាល ថ្នាក់ខេត្ត-ក្រុង ថ្នាក់ស្រុក-ខ័ណ្ឌ នាយកសាលារៀនលើការងារៈ ក) ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ខ) ការពិនិត្យតាមដានកម្មវិធី គ) ការគ្រប់គ្រងព័ត៌មាន និងរបាយការណ៍គ្រប់ប្រភេទ ។

- ក្រសួងកំពុងខិតខំពង្រីកសមត្ថភាពផ្នែកព័ត៌មាន និងបច្ចេកវិទ្យាតាមរយៈ ក) ការពង្រីក website ក្រសួងអប់រំ យុវជន និង កីឡា ខ) ការពង្រីកវិសាលភាពយុទ្ធនាការចុះឈ្មោះចូលរៀន ដោយយកចិត្តទុកដាក់លើសិស្សស្រី និងសិស្សជាជនជាតិភាគតិច គ) បង្កើនការយកចិត្តទុកដាក់លើព័ត៌មានស្តីពីការគ្រប់គ្រងផ្អែកលើលទ្ធផល ។
- ក្រសួងបានពង្រឹងអង្គភាពសវនកម្មផ្ទៃក្នុងរបស់ខ្លួន និងបានដំណើរការសវនកម្មគំរូ (sample audits) នៅតាមអង្គភាពគ្រប់គ្រងថវិកា (BMC) ថ្នាក់កណ្តាល ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងសាលារៀន ។
- ក្រសួងបានខិតខំពង្រឹង និងពង្រីកការពិនិត្យតាមដានការបំពេញការងារវិស័យអប់រំ ជាពិសេសគុណភាព និងប្រសិទ្ធភាពអប់រំ ។
- រៀបចំលិខិតបទដ្ឋានសម្រាប់ការងារគ្រប់គ្រង និងប្រើប្រាស់ថវិកាលើគ្រប់ជំពូកចំណាយ ។
- រៀបចំការប្រជុំផ្លាស់ប្តូរយោបល់ បទពិសោធន៍ និងផ្តល់អនុសាសន៍លើការងារ និងប្រើប្រាស់ថវិកាគ្រប់ជំពូកចំណាយជាពិសេសកម្មវិធីសកម្មភាពជាអាទិភាពនៅតាមខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ ។
- បណ្តុះបណ្តាលមន្ត្រីឯកទេសក្នុងការកសាង និងអនុវត្តកម្មវិធីសិក្សានៅថ្នាក់កណ្តាល និងខេត្ត-ក្រុង ។

បន្ថែមពីនេះទៀត ក្រសួងអប់រំ យុវជន និងកីឡាបានពង្រីកកម្មវិធីបំប៉នរបស់ខ្លួនសម្រាប់ការងារគ្រប់គ្រង និងការពិនិត្យតាមដានរួមមាន : ក) ការបំប៉ននាយកសាលា គ្រូឧទ្ទេស និងអ្នកសម្របសម្រួលកំរងសាលារៀន ខ) ការរៀបចំ

ការងាររដ្ឋបាល និងការគ្រប់គ្រងក្នុងការប្រឡង គ) ការអនុវត្តសាលារៀនកុមារមេត្រី ការអប់រំបញ្ចូលគ្នា និងបរិស្ថានសាលារៀន ឃ) កែលំអការគ្រប់គ្រងកម្មវិធីសកម្មភាពជាអាទិភាពមួយចំនួន ង) បំប៉នសមត្ថភាពកិច្ចការរដ្ឋបាលនៅគ្រប់លំដាប់ថ្នាក់ ច) ពង្រឹងការងារទំនាក់ទំនងរវាងអ្នកផ្តល់ជំនួយអង្គការក្រៅរដ្ឋាភិបាល ជាមួយក្រសួងអប់រំ យុវជន និងកីឡា តាមរយៈការបង្កើតក្រុមការងារបច្ចេកទេសចំរុះក្នុងវិស័យអប់រំ និងការជួបប្រជុំពិភាក្សាទៀងទាត់ ។

## ៣.២. និរន្តរភាពនៃការកសាងសមត្ថភាពសម្រាប់វិមជ្ឈការ

បទពិសោធន៍ដែលទទួលបានគឺ ការផ្តល់សិទ្ធិអំណាច និងទំនួលខុសត្រូវ គឺជាផ្នែកមួយនៃការកសាងសមត្ថភាព និងការរៀបចំកម្មវិធីបណ្តុះបណ្តាលនៅនឹងកន្លែង តាមរយៈកំរងសាលារៀន និងកម្មវិធីបណ្តុះបណ្តាលផ្លូវការ ។ បទពិសោធន៍ផ្សេងទៀតនោះគឺ បានបង្ហាញពីការអនុវត្តនៃការផ្តល់សិទ្ធិអំណាចប្រកបដោយប្រសិទ្ធភាព ដែលទាមទារអោយមានទំនុកចិត្តមាននិរន្តរភាពក្នុងការគាំទ្រថវិកាដំណើរការ និងការផ្តល់ហិរញ្ញប្បទាន ។

ក្នុងបរិបទនេះ ក្រសួងអប់រំ យុវជន និងកីឡាកំពុងអនុវត្តយុទ្ធសាស្ត្រសំខាន់ចំនួន ៤ សម្រាប់ការអភិវឌ្ឍស្ថាប័ន និងកំណែលំអកម្មវិធីកសាងសមត្ថភាពសម្រាប់ធ្វើវិមជ្ឈការការងារអប់រំរួមមាន ក) ពង្រឹងប្រព័ន្ធកសាងផែនការ និងពិនិត្យតាមដាននៅថ្នាក់កណ្តាល ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ កំរងសាលារៀន និងសាលារៀន ខ) លើកកំពស់ប្រព័ន្ធគ្រប់គ្រងការិយាល័យអប់រំស្រុក និងសាលារៀន គ) កែលំអអភិបាលកិច្ចល្អ និងប្រព័ន្ធច្បាប់ ឃ) កែលំអការអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា និងការកសាងសមត្ថភាព ។